ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# សៀវភៅណែនាំបច្ចេកទេស ស្ដីពី
# ការចិញ្ចឹមមាន់ស្រុក



រៀបចំដោយ : នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
សហការជាមួយ : គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប ( TSTD )
ឧបត្ថម្ភដោយ : ធនាគារអភិវឌ្ឍន៍អាស៊ី រដ្ឋាភិបាលប្រទេសហ្វាំងឡង់ និង រដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ

**រៀបរៀងដោយ:**

លោក ស៊ិន ប៉ោ : អ្នកជំនាញផ្នែកបសុសត្វ របស់គម្រោង TSTD

ទូរស័ព្ទលេខ : ០១៧ ៩០៩ ៣៤៥

អ៊ីម៉ែល : porsinn@gmail.com

កាលបរិច្ឆេទ : ខែ សីហា ឆ្នាំ ២០១៣

© រក្សាសិទ្ធិគ្រប់យ៉ាង: គ្រប់ព័ត៌មានទាំងអស់នៃសៀវភៅណែនាំបច្ចេកទេសនេះ
ជាកម្មសិទ្ធិ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ហើយសម្រេចផ្តល់សិទ្ធិឱ្យ
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ធ្វើជាម្ចាស់កម្មសិទ្ធិ។ រាល់សំណើរសុំផលិតបន្ថែម
ត្រូវសុំការអនុញ្ញាតសិទ្ធិជាមុនសិន ពីនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម។

**បុព្វកថា**........iii

**អារម្ភកថា**........1

**១.សេចក្តីផ្តើម**........2
១.១. គោលបំណង........2
១.២. លក្ខណៈល្អប្រសើរនៃការចិញ្ចឹមមាន់ពូជក្នុងស្រុក........2

**២. ទ្រុងសម្រាប់ចិញ្ចឹមមាន់**........3
២.១. ទំហំទីកន្លែងរស់នៅ........3
២.២. ទ្រុងសម្រាប់កូនមាន់........3
២.៣. ទ្រុងសម្រាប់មាន់ធំ........4
២.៤. ស្នូកចំណី និងស្នូកទឹក........7

**៣. ពូជ និង ការបង្កាត់ពូជមាន់**........8
៣.១. ការជ្រើសរើសកូនមាន់ចិញ្ចឹម........8
៣.២. ការជ្រើសរើសបាមាន់........9
៣.៣. ការជ្រើសរើសមេមាន់........9
៣.៤. ការបង្កាត់ពូជមាន់........10

**៤. វដ្តផលិតកម្មមាន់ និងការថែរក្សាកូនមាន់**........10
៤.១. វដ្តផលិតកម្មមាន់........10
៤.២. ការថែរក្សាកូនមាន់ទើបញាស់........11

**៥. ការជម្រុះមាន់**........12

**៦. ចំណីអាហារសម្រាប់មាន់**........13
៦.១. សមាសធាតុចំណីដែលសំបូរជាតិសាច់ (ប្រូតេអ៊ីន)........13
៦.២. សមាសធាតុចំណីដែលសំបូរថាមពល........14
៦.៣. សមាសធាតុចំណីដែលសំបូរជីវជាតិរ៉ែ........14
៦.៤. សមាសធាតុចំណីដែលសំបូរវីតាមីន........15

៦.៥. ការចិញ្ចឹមជន្លេនក្រហមសម្រាប់ជាចំណីបំប៉នបន្ថែម……………………………………16

**៧. ការផ្តល់ចំណីអាហារមាន់**……………………………………………………18
៧.១. ចំណីមេ-បា និងមាន់ធំ…………………………………………………………18
៧.២. ចំណីកូនមាន់…………………………………………………………………19

**៨. ការផ្តល់ទឹក**……………………………………………………………………19

**៩. ជីវសុវត្ថិភាព និងការធ្វើអនាម័យ**………………………………………… 20

៩.១. អនាម័យកន្លែងចិញ្ចឹម............................................................................... 20
៩.២. អនាម័យចំណីអាហារ និងទឹកផឹក…………………………………………20
៩.៣. ការរៀបចំការចិញ្ចឹម…………………………………………………………21
៩.៤. អនាម័យការឆ្លងពីក្រៅ និងឧបករណ៍សម្ភារៈចិញ្ចឹម........................................ 21

**១០. ការការពារជម្ងឺមាន់**…………………………………………………………22
១០.១. ការចាក់ថ្នាំបង្ការ (វ៉ាក់សាំង)..........................................................................22
១០.២. កម្មវិធីទម្លាក់ព្រូន……………………………………………………………23

**១១. ការកត់ត្រាចំណាយចំណូលផលិតកម្ម និង វិភាគសេដ្ឋកិច្ច**…………………23
១១.១. ការកត់ត្រាចំណាយចំណូលផលិតកម្ម..............................................................23
១១.២. ការប្រើប្រាស់ព័ត៌មានប្រមូលបានសម្រាប់វិភាគចំណាយចំណូលផលិតកម្ម……………..25

# បុព្វកថា

អតីតកាល គឺជាការចាប់ផ្តើមមួយ ដែលយើងតែងជួបឧបសគ្គជាច្រើន។ យ៉ាងណាមិញជាមួយនឹងការចាប់ផ្តើម រមែង មានការអភិវឌ្ឍន៍រីកចម្រើនជាជំហានៗ ដើម្បីតភ្ជាប់ជាមួយបច្ចុប្បន្នកាល ហើយរបៀបរបបនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋយើងក៏ចេះតែមានការប្រែប្រួលជាអន្លើៗពីមួយថ្ងៃទៅមួយថ្ងៃ ដែលដើរទន្ទឹមទៅនឹងការវិវឌ្ឍន៍នៃបច្ចេកវិទ្យា ចំណេះដឹង វិទ្យាសាស្ត្រ ឆ្ពោះទៅកាន់ទំនើបភាវូបនីយកម្មពីមួយថ្ងៃទៅមួយថ្ងៃ ក្នុងបរិបទនៃសាកលភាវូបនីយកម្ម។

ពិតណាស់ យើងទាំងអស់គ្នាបានដឹងជាយូរយារណាស់មកហើយថា កម្ពុជាជាប្រទេសកសិកម្ម មានខឿនសេដ្ឋកិច្ចពឹងផ្អែកទៅលើវិស័យកសិកម្ម ហើយដែលរាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងម៉ឺងម៉ាត់បំផុតរបស់ **តេជោសែន** បានចាត់ទុករួចហើយថា "កសិកម្មជាវិស័យអាទិភាពមួយនៅគ្រប់កាលៈទេសៈ"។ ក្នុងន័យនេះ វិស័យកសិកម្ម ត្រូវដើរជាតួអង្គមួយដ៏សំខាន់ក្នុងបរិបទនៃប្រទេសកម្ពុជា ដែលមានប្រជាជនប្រមាណ ៨០% រស់នៅតំបន់ជនបទ និង ប្រកបមុខរបរកសិកម្មបែបនេះនោះ ការអភិវឌ្ឍន៍ក្នុងវិស័យអាទិភាពមួយនេះ ក៏មិនជាការងាយស្រួលប៉ុន្មានឡើយ បន្ទាប់ពីប្រទេសជាតិបានចាកផុតពីសង្គ្រាមស៊ីវិលរាប់ទសវត្សរ៍កន្លងមកនេះ។ ពិសេសដើម្បីធានារ៉ាប់រងក្នុងការបំពេញតម្រូវការរបស់ប្រជាពលរដ្ឋ ក៏ដូចជាការប្រឈមមុខទៅនឹងការកើនឡើងនៃចំនួនប្រជាជន ភាពខុសគ្នានៃតម្រូវការស្បៀងអាហាររបស់អ្នកទីក្រុងផង ការស្រេកឃ្លានស្បៀងអាហាររបស់ប្រជាជនក្នុងពិភពលោកផង និង សម្រាប់ការនាំចេញផងនោះ ពិតជានឹងធ្វើឱ្យខ្សែចង្វាក់នៃបម្រែបម្រួលទាំងអស់នេះ នឹងមានការបង្កើនល្បឿនបន្ថែមទៀតនាអនាគតកាល។

ផ្អែកលើមូលបញ្ហាដូចបានរៀបរាប់ខ្លះៗខាងលើនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសហការជាមួយ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្នុងការអនុវត្ត គម្រោងបង្ហាញបច្ចេកទេសដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប (Tonle Sap Technology Demonstrations For Productivity Enhancement) ពី ខែមីនា ឆ្នាំ២០១០ រហូតដល់ ខែសីហា ឆ្នាំ២០១៣។ ក្នុងចំរវេលានៃការអនុវត្តសកម្មភាពរបស់ខ្លួន គម្រោងTSTD បានធ្វើការសាកល្បងបង្ហាញបច្ចេកវិទ្យាកសិកម្មអំពីការធ្វើពិពិធកម្មដំណាំ ការគ្រប់គ្រងទឹកស្រោចស្រពដំណាំ ការចិញ្ចឹមសត្វ វារីវប្បកម្ម ការផ្តល់សេវាព័ត៌មានជនបទ។ល។ ដើម្បីបង្កើនចំណូលដល់គ្រួសារកសិករខ្នាតតូចក្នុងខេត្តកំពង់ចាម កំពង់ធំ សៀមរាប និង បន្ទាយមានជ័យ។ ក្នុងអំឡុងពេលអនុវត្តគម្រោងជាមួយមន្ទីរកសិកម្មខេត្ត និងខណ្ឌរដ្ឋបាលជលផល ក្នុងខេត្តទាំងបួន គម្រោងបានរៀបចំចងក្រងឯកសារផ្សព្វផ្សាយកសិកម្ម ផ្អែកលើលទ្ធផល និងបទពិសោធន៍អនុវត្តជាក់ស្តែងនៃការបង្ហាញបច្ចេកវិទ្យាកសិកម្ម ជាមួយកសិករនៅតាមមូលដ្ឋាន។

សៀវភៅណែនាំបច្ចេកទេសស្តីពី **ការចិញ្ចឹមមាន់ស្រុក** នេះ បានរៀបចំចងក្រងឡើងដោយអ្នកជំនាញឯកទេស ហើយត្រូវបានឆ្លងការពិនិត្យពិគ្រោះយោបល់ និង ឯកភាពយល់ព្រមពីគណៈកម្មការបច្ចេកទេសដែលមានសមាសភាពមកពីអង្គភាពជំនាញនានា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអ្នកពាក់ព័ន្ធផ្សេងទៀត ហើយ វាជាឯកសារគោល ដែលពិព័ណ៌នាអំពីព័ត៌មាន និងបច្ចេកទេសសម្រាប់មន្ត្រីផ្សព្វផ្សាយស្រុក និងភ្នាក់ងារផ្សព្វផ្សាយបច្ចេកទេសតាមមូលដ្ឋាននានា យកទៅប្រើប្រាស់ជាប្រយោជន៍ក្នុងការបណ្តុះបណ្តាល និង ផ្សព្វផ្សាយបច្ចេកទេសថ្មីៗ ក្នុងបំណងផ្ទេរចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យាកសិកម្មតាមគ្រប់រូបភាពឱ្យបានជ្រួតជ្រាបដល់ប្រជាកសិករ និង

ផលិតករ ដែលរស់នៅក្នុងតំបន់មានសក្តានុពលភាពសមស្របតាមល័ក្ខខ័ណ្ឌភូមិសាស្ត្រ សេដ្ឋ-កិច្ចសង្គម និងតម្រូវការចាំបាច់ជាក់លាក់នៅមូលដ្ឋាន។

ជារួម សៀវភៅណែនាំបច្ចេកទេសនេះ មានសារប្រយោជន៍សម្រាប់មន្ត្រីកសិកម្មខេត្ត ក្រុង ស្រុក អង្គការក្រៅរដ្ឋាភិបាល ភ្នាក់ងារប្រតិបត្តិការនានានៅមូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់យកទៅប្រើប្រាស់ក្នុងការផ្ទេរបច្ចេកវិទ្យាដល់ប្រជាកសិករជនបទ ឱ្យបានទូលំទូលាយ និងចូលរួមដោះស្រាយបញ្ហាចំពោះមុខ ដែលប្រជាកសិករកំពុងប្រឈមនៅក្នុងការងារផលិតកម្មកសិកម្ម ពិពិធកម្មកសិកម្ម ដើម្បីធានាសន្តិសុខស្បៀង និងបង្កើនប្រាក់ចំណូលគ្រួសារជាពិសេស រួមចំណែកកាត់បន្ថយភាពក្រីក្រស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។ ឯកសារនេះ ជាបរិវិសទានមួយ ជួយបើកផ្លូវដល់ប្រិយមិត្តអ្នកអានទាំងឡាយ ដែលមានបំណងយកបច្ចេកទេសនេះ ទៅអនុវត្តតាមសេចក្តីសម្រេចចិត្តរបស់ខ្លួន និងទទួលបានផ្លែផ្កាល្អប្រសើរប្រកបដោយក្តីសង្ឃឹម។ យើងខ្ញុំរីករាយ និង រង់ចាំទទួលនូវការរិះគន់កែលម្អ ក្នុងន័យស្ថាបនាពីសំណាក់ប្រិយមិត្តអ្នកអានទាំងឡាយ ដើម្បីញ៉ាំងឱ្យការចងក្រងលើកក្រោយៗកាន់តែមានភាពសុក្រឹតថែមទៀត។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែ សីហា ឆ្នាំ២០១៣

**រដ្ឋមន្ត្រី**

ច័ន្ទ-សារុន

# អារម្ភកថា

គម្រោងបង្ហាញបច្ចេកវិទ្យា ដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប (TSTD – TA 7305-CAM) ជាគម្រោងជំនួយ បច្ចេកទេស ដែលផ្ដល់សហ-ហិរញ្ញប្បទានឥតសំណងសម្រាប់អនុវត្ត ដោយរដ្ឋាភិបាលហ្វាំងឡង់ មូលនិធិដៃគូអ៊ី-អាស៊ី និងចែករំលែកពុទ្ធិនៃសាធារណៈរដ្ឋកូរ៉េ និង ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ។ រាជរដ្ឋាភិបាលកម្ពុជា ចូលរួមបដិភាគមិនមែនជាថវិកា (ធនធានមនុស្ស ការិយាល័យបំពេញការងារ......) សម្រាប់អនុវត្តគម្រោង។ ធនាគារអភិវឌ្ឍន៍អាស៊ី ជាអ្នកចាត់ចែងប្រតិបត្តិការផ្ទាល់ ជំនួសមុខឱ្យម្ចាស់ជំនួយ។ គម្រោង បានធ្វើការសាកល្បងបង្ហាញបច្ចេកវិទ្យាកសិកម្ម និង ផ្ដល់សេវាព័ត៌មានជនបទ ដើម្បីបង្កើន និង ពង្រីកប្រាក់ប្រភពចំណូលរបស់គ្រួសារកសិករខ្នាតតូច ក្នុងខេត្ត កំពង់ចាម កំពង់ធំ សៀមរាប និង បន្ទាយមានជ័យ ។

សៀវភៅណែនាំបច្ចេកទេសស្ដីពី **ការចិញ្ចឹមមាន់ស្រុក** នេះត្រូវបានរៀបចំឡើង ដើម្បីផ្ដល់នូវមូលដ្ឋានចំណេះដឹងសម្រាប់ជួយដល់កសិករ ក្នុងការចិញ្ចឹមមាន់ពូជក្នុងស្រុក សម្រាប់លក់ ទៅតាមលក្ខណៈបច្ចេកទេសសមស្របឱ្យទទួលបានជោគជ័យ លើកស្ទួយផលិតកម្មមាន់ឱ្យបានរីកចម្រើន និង បង្កើនប្រាក់ចំណូលគ្រួសារ។

ខ្លឹមសារក្នុងសៀវភៅណែនាំបច្ចេកទេសនេះ ត្រូវបានរៀបចំឡើងសម្រាប់កសិករ ដែលចង់ចិញ្ចឹមមាន់ស្រុក ដោយផ្អែកលើជំហាននៃការអនុវត្តន៍បច្ចេកទេស និង បទពិសោធន៍បានអនុវត្តជាក់ស្ដែងទទួលបាន ជោគជ័យក្នុងកម្មវិធីធ្វើបង្ហាញបច្ចេកទេសចិញ្ចឹមមាន់ តាមទីតាំងប្រហែលចំនួន១០០ កន្លែង ក្នុងខេត្តគោលដៅរបស់គម្រោង។

សៀវភៅនេះ បង្ហាញពីវិធីសាស្ត្រចិញ្ចឹមតាមលក្ខណៈបច្ចេកទេស សមស្រប និង បទពិសោធន៍អនុវត្តបាន ជោគជ័យ ក្នុងតំបន់ដែលតែងជួបប្រទះបញ្ហាជាច្រើន ដូចជា អត្រាកំណើនយឺត មាន់ក្រិន ជម្ងឺ និង ងាប់ច្រើន ជាដើម ។ តាមរយៈបច្ចេកទេសនេះ កសិករអាចចិញ្ចឹមមាន់បានលក់ ជារៀងរាល់ខែ ឬក៏ ញឹកញាប់ជាងនេះ ។

ដើម្បីទទួលបានទិន្នផលខ្ពស់ និងប្រាក់ចំណេញកាន់តែប្រសើរឡើងនោះ កសិករចាំបាច់ត្រូវតែទទួលយក និង អនុវត្តបានខ្ជាប់ខ្ជួននូវបច្ចេកទេសដែលបានបង្ហាញ ដើម្បីកាត់បន្ថយអត្រាងាប់ និងជួយឱ្យការចិញ្ចឹមមាន់ បានធំធាត់បានល្អប្រសើរឡើង ។ សៀវភៅនេះមានបញ្ចូលបច្ចេកទេសស្ដីពី របៀបសាងសង់ទ្រុង ការជ្រើសរើសពូជ ការផ្ដល់ចំណីអាហារ និង វិធានការណ៍ការការពារបែបជីវៈសុវត្ថិភាព និង វ៉ាក់សាំងការពារជម្ងឺឆ្លង ជាដើម។

ការអនុវត្តន៍កម្មវិធីបណ្ដុះបណ្ដាល និង ធ្វើបង្ហាញពី បច្ចេកទេសចិញ្ចឹមមាន់ នេះ អាចទទួលបានជោគជ័យ ដោយមានការគាំទ្រពីបុគ្គលិកគម្រោង TSTD លោក ប្រាក់ ថាវអមិដា ប្រធានសម្របសម្រួលគម្រោង និង ជាអគ្គលេខាធិការរងនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ លោក លីវ លាងហ៊ី ប្រធានក្រុមទីប្រឹក្សាគម្រោង នៃក្រុមហ៊ុនផ្ដល់ប្រឹក្សា NIRAS និង ថ្នាក់ដឹកនាំ និងមន្ត្រីនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល និង មន្ត្រីមន្ទីរកសិកម្មខេត្ត ទាំងបួន។

**អ្នករៀបរៀង**

ស៊ិន ប៉ោ អ្នកជំនាញផ្នែកបសុសត្វ របស់គម្រោង TSTD

អ៊ីម៉េល: porsinn@gmail.com

## ១. សេចក្តីផ្តើម

ការចិញ្ចឹមមាន់ស្រុក បានផ្តល់នូវចំណូលបន្ថែមជាប្រចាំខែដល់គ្រួសារ ដោយចំណាយពេលទំនេរ និង ធនធានមួយចំនួនប៉ុណ្ណោះ ។ ពូជមាន់ក្នុងស្រុកមានការពេញនិយមពីអ្នកបរិភោគ មានតម្រូវការទីផ្សារខ្ពស់ និងងាយស្រួលលក់(មានតម្លៃថ្លៃ)។ ទន្ទឹមនឹងការចិញ្ចឹមនេះ កសិករនៅតែអាចប្រកបរបរ ឬ ការងារផ្សេងទៀតបាន ។ តាមបទពិសោធន៍កន្លងមក កសិករចិញ្ចឹមមាន់មេ និងបា ២១ ក្បាល (មេ ១៨ និង បា ៣) អាចទទួលផលមាន់ចំនួន ៥០គីឡូ សម្រាប់លក់ក្នុង ១ខែ១ (បន្ទាប់ពីដាក់ចិញ្ចឹមមេបា បានរយៈពេល ចាប់ពី ៥ ខែឡើងទៅ) ហើយបានចំណូលសរុបជាមធ្យម ៨០ម៉ឺនរៀល ។ កសិករអាចទទួលបានប្រាក់ចំណេញសុទ្ធជាមធ្យម ពី ៣០ ទៅ ៤០ ម៉ឺនរៀល ក្នុង ១ខែ១ ។ ប្រាក់ចំណូលនេះ នឹងកើនឡើងបន្ថែមទៀត បើកសិករបង្កើនចំនួនមេបាមាន់ ។ តាមបច្ចេកទេសចិញ្ចឹមថ្មីនេះ មេមាន់ ១ ក្បាល អាចផលិតកូនបានពី ៦ ទៅ ៧សំបុក ក្នុង ១ឆ្នាំ ហើយកូនមាន់មិនងាប់ ចិញ្ចឹមបានរស់ដល់ធំ ក្នុងរយៈពេលតែ ១០៥ថ្ងៃ ដែលមាន ទម្ងន់ជាមធ្យម ១,២ គីឡូក្រាម ក្នុង ១ ក្បាល ។

### *១.១. គោលបំណង*

- ដើម្បីបង្ហាញ និងផ្សព្វផ្សាយ បច្ចេកវិទ្យាចិញ្ចឹមមាន់សមស្រប ដល់កសិករ
- ពង្រីកការចិញ្ចឹមទៅតាមតម្រូវការទីផ្សារ និង បង្កើតមុខរបរ និងប្រាក់ចំណូលគ្រួសារ
- ចិញ្ចឹមតាមបច្ចេកទេសជីវសុវត្ថិភាព អាចកាត់បន្ថយការឆ្លងរាលដាលជម្ងឺមាន់
- ងាយស្រួលក្នុងការគ្រប់គ្រង (ការផ្តល់ចំណី ការបង្កាត់ពូជ ការការពារ និងអនាម័យ)
- ផ្តល់សាច់ និងស៊ុត (ពង) ធ្វើជាម្ហូបអាហារដែលមានគុណភាពល្អ
- ផ្តល់លាមក សម្រាប់ធ្វើជីដាក់ដំណាំ

### *១.២. លក្ខណៈល្អប្រសើរនៃការចិញ្ចឹមមាន់ពូជក្នុងស្រុក*

ពូជមាន់ដែលប្រទះឃើញញឹកញាប់ជាងគេ គឺ មាន់គក មាន់សំពៅ មាន់ប្រជល់ មាន់កណ្តុង មាន់ចៃ មាន់សំឡីមាន់ក្រញាស់ មាន់ខ្មៅ មាន់ស្លួយ មាន់ក្លឹង។ល។ គុណសម្បត្តិនៃការចិញ្ចឹមមាន់ពូជក្នុងស្រុក ៖

- ធន់ទ្រាំទៅនឹងអាកាសធាតុ និងការលំបាកគ្រប់បែបយ៉ាង
- មិនចាំបាច់ផ្តល់នូវចំណីផ្សំ (ក្រុមហ៊ុន) ទាំងស្រុង ដោយអាចផ្សំពីចំណីធម្មជាតិ ដែលអាចរកបាននៅក្នុងភូមិ និងមានតម្លៃថោកសមរម្យ
- ងាយស្រួលក្នុងការថែទាំ។ ផ្តល់ពង ក្រាបភ្ញាស់ និងបណ្តើរកូនដោយខ្លួនវា
- មិនសូវកើតជម្ងឺ និងទប់ទល់ជាមួយជម្ងឺកាចសាហាវបានមួយចំនួន
- សាច់មាន់ស្រុកមានរសជាតិឆ្ងាញ់ និងពេញនិយម
- តម្រូវការទីផ្សារខ្ពស់ (មាន់សាច់ និងពង) និងមានតំលៃល្អ

## ២. ទ្រុងសម្រាប់ចិញ្ចឹមមាន់

*តើត្រូវធ្វើទ្រុងមាន់យ៉ាងដូចម្តេច ដើម្បីឱ្យការចិញ្ចឹមទទួលបានជោគជ័យល្អ?*

ទ្រុងមានសារៈសំខាន់ណាស់សម្រាប់ការពារមាន់ធំ និង កូនមាន់ពីការយាយីបំផ្លាញផ្សេងៗ និង អាចទប់ទល់អាកាសធាតុប្រែប្រួល ជាពិសេសសម្រាប់កូនមាន់តូចៗ ។ ទ្រុងមាន់ដែលល្អ ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- ទីធ្លាទូលាយ ហើយ មានខ្យល់អាកាសស្រឡះល្អ និងស្ងួត
- ងាយស្រួលក្នុងការបោសសំអាត និង អនាម័យ
- មានទ្រនំសម្រាប់មាន់ដេក
- មានសំបុកគ្រប់គ្រាន់សម្រាប់មេមាន់ពង និង ក្រាបពង
- ការពារពីការយាយី បំផ្លាញផ្សេងៗ

ដើម្បីឱ្យការចិញ្ចឹមមាន់បានរីកចំរើន និង ធានាសុវត្ថិភាពនោះ កសិករត្រូវអនុវត្តតាមបច្ចេកទេសសំខាន់ៗ មួយចំនួន ដូចខាងក្រោម៖

### *២.១. ទំហំទីកន្លែងរស់នៅ*

សម្រាប់មេមាន់មួយក្បាល និង កូនមាន់ពី ១៥ ទៅ ២០ក្បាល ត្រូវការទំហំផ្ទៃដី ១,៥ម៉ែត្រ គុណ ១,៥ម៉ែត្រ។ ដូច្នេះ បើចិញ្ចឹមមេមាន់ ២០ក្បាល កសិករត្រូវមានផ្ទៃដីប្រហែលពី ៦០ ទៅ ៨០ ម២ (ម៉ែត្រការ៉េ) ហើយដើម្បីឱ្យមានកូនមាន់ ច្រើន និងចិញ្ចឹមបំប៉នរហូតដល់ពេលលក់ មានសុខភាពល្អ កសិករត្រូវមានដីពី ១០០ ទៅ ១២០ ម៉ែត្រការ៉េ។

### *២.២. ទ្រុងសម្រាប់កូនមាន់*

តើត្រូវធ្វើទ្រុងកូនមាន់អាយុពី ១ ទៅ ៣០ថ្ងៃ យ៉ាងដូចម្តេចដើម្បីឱ្យលូតលាស់ល្អ?

- ធ្វើទ្រុងផុតពីដីកំពស់ កន្លះម៉ែត្រ (៥តឹក)
- បាតទ្រុង និងជញ្ជាំងអាចធ្វើពីបន្ទះឬស្សី ឬ សំណាញ់ដែក ឬ សំណាញ់នីឡុង។
- បាតទ្រុងក្រាលអង្កាម ឬកំទេចអាចម៍រណា (ដើម្បីរក្សាកំដៅ) រហូតដល់កូនមាន់មានអាយុ ៣០ថ្ងៃ ឬ ១ ខែ ទើបលែងដាក់។
- ជញ្ជាំងទ្រុង និងពីលើទ្រុងព័ទ្ធដោយបាវ ឬ ក្រដាស ដើម្បីរក្សាកំដៅ ពិសេសពេលយប់ និង អាកាសធាតុត្រជាក់។

> *បញ្ជាក់: ពេលកូនមាន់អាយុបាន ៣០ថ្ងៃ ត្រូវបញ្ជូនទៅដាក់ក្នុងទ្រុងបំប៉ន រហូតដល់ពេលលក់។*





រូបទី១: ទ្រុងកូនមាន់ជញ្ជាំងធ្វើពីបន្ទះរនាបឬស្សី រូបទី២: ទ្រុងកូនមាន់ជញ្ជាំងធ្វើពីសំណាញ់





រូបទី៣: ទ្រុងកូនមាន់បាំងជុំវិញសម្រាប់រក្សាកំដៅ រូបទី៤: សំយាបរោងសម្រាប់ដាក់ទ្រុងកូនមាន់

## ២.៣. ទ្រុងសម្រាប់មាន់ធំ

ការចិញ្ចឹមមាន់មាន ២ យ៉ាងសំខាន់ៗ គឺ ចិញ្ចឹមលែង និងចិញ្ចឹមដាក់ទ្រុង។ តើយើងត្រូវចិញ្ចឹមមាន់ក្នុងសណ្ឋានទ្រុងទីធ្លាបិទជិតយ៉ាងដូចម្ដេច? សណ្ឋានទ្រុងនេះ គឺ នៅពេលយប់បញ្ចូលមាន់ឱ្យដេកនៅក្នុងទ្រុង រីឯពេលថ្ងៃ ព្រលែងឱ្យដើរស៊ី ក្នុងរបងសំណាញ់បិទជិត។ គុណសម្បត្តិនៃការចិញ្ចឹមរបៀបនេះ គឺ៖

- ងាយស្រួលក្នុងការគ្រប់គ្រង
- ងាយស្រួលក្នុងការផ្ដល់ចំណី និងការថែទាំ
- ងាយស្រួលក្នុងការចាក់ថ្នាំការពារ និងការតាមដានជម្ងឺ
- ការពារការឆ្លងរាលដាលនៃជម្ងឺ ដែលឆ្លងរាតត្បាតពីខាងក្រៅ
- ការពារ និងរារាំងពីការបំផ្លាញដោយសត្វផ្សេងៗ

ប៉ុន្តែទ្រុងរបៀបនេះ ត្រូវការចំណាយដើមទុនច្រើនក្នុងការសាងសង់ និង ធ្វើរបងព័ទ្ធជុំវិញ សម្រាប់ឱ្យមាន់ ដើរខាងក្នុងទ្រុង ។ ហើយម្យ៉ាងទៀត ត្រូវចំណាយចំណីស្ទើរតែទាំងស្រុង សម្រាប់ផ្ដល់ឱ្យមាន់ស៊ី។

## ក. ការសាងសង់ទ្រុងមាន់

ទ្រុងមានសារៈសំខាន់ណាស់ សម្រាប់ការពារសត្វ (មាន់) ឱ្យចៀសផុតពីកត្តាចង្រៃផ្សេងៗ ដែលមកយាយី ។ ហេតុនេះ ទ្រុងត្រូវសាងសង់ឱ្យបានត្រឹមត្រូវ តាមបច្ចេកទេស ។ ដំបូងកសិករជ្រើសរើសទីកន្លែងដែលមានទីទួល ឬ មិនលិចទឹកហើយចាក់ដីបំពេញឱ្យខ្ពស់ជាងផ្ទៃដីធម្មតា និង បុកបង្ហាប់ល្អ ដើម្បីចៀសវាងកុំឱ្យទឹកភ្លៀងហូរកាត់ក្នុងទ្រុង ។ ចំពោះផ្ទៃដីដែលចាក់ នេះត្រូវធំជាងតួរោង ០,៥ ម៉ែត្រ (៥តឹក) ជុំវិញ។

- ទំហំរោងមាន់ (ទ្រុងដេកយប់) ៥ ម៉ែត្រ x ១០ ម៉ែត្រ ដែលចែកជាខ័ណ្ឌៗដោយសំណាញ់
- ខាងក្រៅរោងដេកយប់ មានព័ទ្ធដោយសំណាញ់ ជាខណ្ឌៗ កុំឱ្យមាន់ចេញក្រៅ
- តួរោង និង សសរធ្វើពីឈើ
- ជញ្ជាំងទ្រុងធ្វើពីបន្ទះឬស្សី ដែលគម្លាតពីមួយ ទៅមួយ មានប្រវែង ១ សង់ទីម៉ែត្រ
- ទ្រុងត្រូវមានកំពស់ជើងរៀង ១,៧ ម៉ែត្រ និងសសរកន្លោងកំពស់ ៣,២ ម៉ែត្រ
- ដំបូលគួរធ្វើពីស្បូវ ឬ ពីស្លឹកត្នោត
- គ្រោងទ្វារធ្វើពីកូនឈើ ឬ ពីឬស្សី
- រៀបចំធ្នើរឱ្យមាន់ដេកកំពស់ ពី ៦០ ទៅ ៧០ សង់ទីម៉ែត្រ ពីដី និងមានបន្ទាធ្នើរ ៧០ សង់ទីម៉ែត្រ (៧តឹក)
- សំបុកសម្រាប់មេមាន់ពង ត្រូវនៅខ្ពស់ជាងសំបុក
- ត្រូវធ្វើជណ្ដើរ សម្រាប់ឱ្យមេមាន់ ឡើងក្រាបពង និង មាន់ ឡើងដេក។




រូបទី៥: ពំនូសកាត់គំរូទ្រុងមាន់សណ្ឋានទ្រុងទីធ្លាបិទជិត (មើលចំពីលើ)



រូបទី៦: គំរូតួរោងទ្រុងមាន់ (មើលចំពីលើ)



រូបទី៧: តួរោងទាំងមូលរបស់ទ្រុងមាន់

ជាការល្អ ត្រូវដាំដើមកន្ធំថេត ដំឡូងឈើ ត្រកួន...នៅជុំវិញទ្រុង ដើម្បីផ្តល់ជាអាហារបន្ថែមដ៏ល្អ សម្រាប់មាន់។

## ខ.ទ្រនំ ឬ ផ្ទើរសម្រាប់មាន់ដេក

- យើងធ្វើទ្រនំដើម្បីងាយស្រួលប្រមូលលាមកធ្វើជី និងងាយស្រួលសំអាត
- ទ្រនំ ត្រូវទាបជាងសំបុក
- ចន្លោះផ្ទើរ (ទ្រនំ) មានប្រវែង ១៥សង់ទីម៉ែត្រ (ឬ ១,៥ តឹក)





រូបទី៨: ផ្ទើរសម្រាប់មាន់ដេក ធ្វើពីបន្ទះឬស្សី

## គ. សំបុកមេមាន់

- ត្រូវរៀបចំសំបុក មុនមាន់រកពង
- ចំនួនសំបុក ត្រូវឱ្យស៊ីគ្នាជាមួយចំនួនមេមាន់
- សំបុកអាចធ្វើពីបង្គី ឬស្បូ កេស ។ល។
- សំបុកដាក់ ឬ ចងជាប់នឹងទ្រុង នៅកន្លែងមិនសូវមានពន្លឺ
- ក្នុងសំបុកដាក់ចំបើងស្ងួតហើយក្រាស់ ដែលធានាការរក្សាកំដៅគ្រប់គ្រាន់
- ដើម្បីកំចាត់ស្រមើរក្នុងសំបុក ត្រូវដាក់កំទេចថ្នាំជក់ ស្លឹកចេក ឬ ស្លឹកសាវម៉ាវព្រៃ នៅពីក្រោមសំបុក។




រូបទី៩: សំបុកសម្រាប់មេមាន់ពង

## ២.៤. ស្នូកចំណី និង ស្នូកទឹក

ត្រូវដាក់ស្នូកទឹក និងស្នូកចំណី ឱ្យបានគ្រប់គ្រាន់សម្រាប់មាន់ ។ ដើម្បីកាត់បន្ថយការចំណាយទិញ និងការកំពប់បាត់បង់ចំណី កសិករគួរកែច្នៃនូវសម្ភារៈដែលមានស្រាប់ នៅក្នុងភូមិ ឬ មានតម្លៃថោកៗ សម្រាប់ធ្វើជា ស្នូកចំណី ។ អ្នកចិញ្ចឹមមាន់ អាចយកប៊ីដុង ឬ កានជ័រចាស់ មកច្នៃជាស្នូកចំណី ដូចដែលបង្ហាញ ក្នុងរូបខាងក្រោម៖



រូបទី១០: ស្នូកចំណីកូនមាន់ ធ្វើពីដបជ័រ



រូបទី១១: ស្នូកចំណីកូនមាន់ជំទង់ ធ្វើពីប៊ីដុងជ័រ



រូបទី១២: ស្នូកចំណីកូនមាន់ជំទង់ ធ្វើពីធុងជ័រ



រូបទី១៣: ស្នូកចំណីមាន់ធំ ធ្វើពីប៊ីដុងជ័រ





រូបទី១៤: ស្នូកទឹកសម្រាប់មាន់ផឹក

## ៣. ពូជ និង ការបង្កាត់ពូជមាន់

ពូជមាន់ក្នុងស្រុក មានលក្ខណៈសម្បត្តិសមស្របសម្រាប់កសិករចិញ្ចឹម និងពង្រីកផលិតកម្ម។ តើត្រូវជ្រើសរើសពូជមាន់សម្រាប់ចិញ្ចឹម តាមរបៀបណា ទើបបានត្រឹមត្រូវ?

### ៣.១. ការជ្រើសរើសកូនមាន់ចិញ្ចឹម

- រាងល្អ ភ្លៀវភ្លា ជើងលឿង
- ចេញពីមេបា ដែលមានសុខភាពល្អ
- ចំពោះកូនមាន់ ដែលរោមស្អិតជាប់គ្នា ហើយពោះធ្លាក់ ឬ រឹង និងមានពណ៌ខៀវ មិនគួរយកមកចិញ្ចឹមទេ



រូបទី១៥: កូនមាន់មានសភាពរស់រវើកនិងភ្លៀវភ្លា

## ៣.២. ការជ្រើសរើសបាមាន់

- រាងល្អ ក្លៀវក្លា ជើងលឿង
- ខ្នាយប្រវែង ២ ទៅ ៣ សង់ទីម៉ែត្រ ទម្ងន់ ២,៥ គីឡូក្រាម។
- មានអាយុចាប់ពី ៩ ខែ តែមិនត្រូវឱ្យលើសពី ៣ ឆ្នាំឡើយ។
- មានមេបា ដែលមានកូនច្រើន និងគ្មានជម្ងឺឆ្លង



រូបទី១៦: បាមាន់មានមាឌធំ និងសុខភាពល្អ

## ៣.៣. ការជ្រើសរើសមេមាន់

- រាងល្អ ខ្លាំងមាំ ជើងលឿង
- គ្មានជម្ងឺ និងសុខភាពល្អ
- ត្រូវមានអាយុ ៧ ខែឡើង និងមានទម្ងន់ច្រើនជាង ១,២ គីឡូក្រាម
- រើសចេញពីមេមាន់ដែលបានផ្តល់កូន ៤ សារ ក្នុងមួយឆ្នាំយ៉ាងតិច
- ពងមួយសារពី ១០ ទៅ ១២ ពង ហើយអត្រាញាស់ ពី ៨ ក្បាល ឡើង ហើយដែលកូនមាន់ ទាំងនោះ សកម្ម និង ក្លៀវក្លា។





រូបទី១៧: ពូជមេមាន់មានមាឌធំ និងជើងសម្បុរមៀត

📖 សំគាល់: មេ និងបា គួរមានស្រការជើងក្រាស់ល្អ ជើងមាំ សិរក្រហម ស្បែកកស្តើងទន់ ។ បា ១ សម្រាប់ មេ ពី ៥ ទៅ ៧ ក្បាល។ ប៉ុន្តែជាការប្រសើរគួរតែដាក់បា ១ ក្បាល ជាមួយមេ ៦ ក្បាល។

☛ *ត្រូវជ្រើសរើសកូន ពី២ ទៅ ៣ ក្បាល ពីមេបាល្អ ក្នុងមួយជំនាន់សម្រាប់ទុកពូជបន្ត!*

### ៣.៤. ការបង្កាត់ពូជមាន់

យើងអាចជ្រើសរើសពូជមាន់មកចិញ្ចឹម អាស្រ័យលើគោលបំណងរបស់អ្នកចិញ្ចឹម ។ ពូជមាន់ក្នុងស្រុក មានលក្ខណៈសមស្របបំផុត សម្រាប់ស្ថានភាពកសិករ ក្នុងពេលបច្ចុប្បន្ននេះ ។ បើអ្នកចិញ្ចឹម ចង់បានផលិតកម្មសាច់ខ្ពស់ និង លូតលាស់លឿន ត្រូវយកពូជមាន់មេក្នុងស្រុកបង្កាត់ជាមួយ ពូជកូនកាត់ នាំចូល ។ ឧទាហរណ៍: ពូជកូនកាត់ អ៊ីសាប្រោន (ខេអាយ) ជាដើម។ ប៉ុន្តែត្រូវជ្រើសរើសប្រភេទ ពូជនាំចូលដែលមានសម្បុរប្រហាក់ប្រហែលពូជក្នុងស្រុក ទើបងាយស្រួលលក់ និងមានតម្រូវការសម្រាប់ ទីផ្សារខ្ពស់ ។

## ៤. វដ្តផលិតកម្មមាន់ និងការថែរក្សាកូនមាន់

### ៤.១. វដ្តផលិតកម្មមាន់

វដ្តផលិតកម្ម ឬ រយៈពេលញាស់មួយសំបុករបស់មេមាន់ ១ ក្បាល មានរយៈពេល ៥៦ថ្ងៃ ប្រសិនបើអ្នកចិញ្ចឹមអនុវត្តតាមបច្ចេកទេស ដូចបង្ហាញខាងក្រោម ។ ដូច្នេះមេមាន់ ១ ក្បាល អាចទទួលបានកូនមាន់ជាមធ្យម ពី ៥ ទៅ ៦ សំបុក ក្នុង ១ឆ្នាំ។




រូបទី១៨: គំនូសតាងវដ្តផលិតកម្មមាន់

*សំគាល់:* បើសិនជាកសិករមានបទពិសោធន៍គ្រប់គ្រាន់នោះ កសិករអាចបំបែកកូន ចេញពីមេ បន្ទាប់ពីញាស់រួចភ្លាម ។ ដូចច្នេះ ក្នុង ១ឆ្នាំ កសិករអាចទទួលបានកូនមាន់ពី ៧ ទៅ ៨ សំបុក សម្រាប់មេមួយក្បាល ។ ប៉ុន្តែកូនមាន់ទាំងនោះ ត្រូវការថែរក្សាយ៉ាងត្រឹមត្រូវ។

## ៤.២. ការថែរក្សាកូនមាន់ទើបញាស់

កូនមាន់ដែលទើបញាស់ ងាយនឹងរងគ្រោះ និង អត្រាងាប់ខ្ពស់ ប្រសិនបើមិនបានថែរក្សាត្រឹមត្រូវ ។ ដូច្នេះ ដើម្បីការពារកូនមាន់កុំឱ្យងាប់ ត្រូវអនុវត្តដូចខាងក្រោម៖

- ថែរក្សានៅកន្លែងដែលមានសុវត្ថិភាព
- កន្លែងដែលមានបរិយាកាសក្តៅល្មម និងស្អាតល្អ
- ផ្តល់នូវទឹក និងចំណីអាហារ ដែលងាយស្រួលរំលាយ និងគ្រាប់ល្អិតៗ គ្រប់គ្រាន់។

### *តើយើងត្រូវបំបែកកូនមាន់ ចេញពីមេនៅអាយុ ១០ថ្ងៃ យ៉ាងដូចម្តេច ?*

ក. រៀបចំទ្រុងសម្រាប់ដាក់កូនមាន់រួចជាស្រេច ដោយបាតទ្រុងដាក់អង្កាម ឬ កំទេចអាចម៍រណារ

ខ. ត្រូវយកទាំងមេ និងកូន ទៅដាក់ក្នុងទ្រុងកូនមាន់ជាមួយគ្នា ក្រោយពីកូនញាស់អស់

គ. ពេលកូនមាន់អាយុបាន ១០ថ្ងៃ ត្រូវដកមេចេញពីកូន ដោយយកទៅដាក់ក្នុងទ្រុងមេពង ។ មិនត្រូវឱ្យមេមាន់ចូលក្នុងទ្រុង ឬ មកក្បែរ កូនមាន់ ដែលកំពុងបំបែកពីមេឡើយ។

ឃ. ត្រូវយកបាវ ឬ ក្រដាសព័ទ្ធជុំវិញទ្រុងកូនមាន់ ដើម្បីរក្សាកំដៅ ។ បើសិនត្រជាក់ខ្លាំង ឬ ពេលយប់ ត្រូវបន្ថែមកំដៅដោយប្រើក្អមធ្យូងកំដៅ ឬ អំពូលភ្លើង (មូល) ១០០វ៉ាត់។

ង. កូនមាន់អាយុបាន ១ខែ ត្រូវយកទៅចិញ្ចឹមនៅក្នុងទ្រុងបំប៉ន រហូតដល់ពេលធំ អាចចាប់លក់បាន។

### *តើយើងថែរក្សាកូនមាន់យ៉ាងដូចម្តេច ដើម្បីឱ្យបានល្អ?*

- *ការក្រុងរបស់មេ:* បើសិនមេមាន់ វាក្រុងកូនរបស់វាក្រោមស្លាប នោះកូនមាន់ នឹងទទួលកំដៅពីមេវា រវាងពី ៣៥ ទៅ ៣៧ អង្សាសេ។

- *ការចិញ្ចឹមគ្មានមេ:* ត្រូវផ្តល់កំដៅឱ្យកូនមាន់ ដូចមេមាន់ដែរ
  - បើសីតុណ្ហភាពទាប នោះកូនមាន់នឹងខ្សោយ រងារ ឈឺ ហើយបណ្តាលឱ្យការលូតលាស់យឺត
  - បើសីតុណ្ហភាពខ្ពស់ នឹងធ្វើឱ្យរោមកូនមាន់ដុះមិនល្អ
  - ត្រូវត្រៀមកំដៅសម្រាប់កូនមាន់
  - ត្រូវផ្តល់ទឹក និងចំណីឱ្យបានគ្រប់គ្រាន់ និងមានគុណភាព





រូបទី១៩: ផ្តល់កំដៅកូនមាន់ដោយប្រើរងើកធ្យូង  រូបទី២០: ផ្តល់កំដៅកូនមាន់ដោយប្រើអំពូលភ្លើង

❖ សញ្ញាបង្ហាញពីកំដៅក្នុងទ្រុងកូនមាន់
- ➢ កំដៅល្មមគ្រប់គ្រាន់: កូនមាន់ដើររកស៊ីរាយប៉ាយល្អ ក្នុងទ្រុង
- ➢ កំដៅខ្លាំងជ្រុល: កូនមាន់ឃ្លាតឆ្ងាយពីប្រភពកំដៅ ឬ ស្រែកយំពេញទ្រុង ឬ រត់ប្រសេចប្រសាច
- ➢ កំដៅត្រជាក់ខ្លាំង: កូនមាន់ប្រមូលផ្តុំគ្នា ឬ គរលើគ្នា




រូបទី២១: សញ្ញាបង្ហាញពីការទទួលកំដៅរបស់កូនមាន់

## ៥. ការជម្រុះមាន់

តាមធម្មតា កសិករមិនដែលជម្រុះមាន់ទេ លើកលែងតែវាងាប់ ឬ ឈឺ ដោយសារជម្ងឺ ។ ការទុកមេបាមាន់ចិញ្ចឹមរហូតដល់អាយុច្រើនជាង ៣ឆ្នាំ វាមិនអាចផ្តល់លទ្ធផលល្អទេ ព្រោះវាអាចធ្វើឱ្យមេមាន់ ផ្តល់ពងតិច និង អត្រានៃការញាស់តិចដែរ និង ជាពិសេសអត្រាងាប់ខ្ពស់។ ដូច្នេះដើម្បីឱ្យទទួលបាននូវលទ្ធផលល្អ គួរតែអនុវត្ត ដូចខាងក្រោម ៖

- ជម្រុះមេមាន់ និងបា មិនឱ្យអាយុលើសពីអាយុ ៣ឆ្នាំ
- បើសិនជាទុកមេត្រូវផ្លាស់ប្តូរបាចេញ ដោយទិញបាថ្មីមកជំនួសវិញ តែត្រូវប្រយ័ត្នការជាន់ឈាមចំពោះបាថ្មី និង មានផ្ទុកនូវជម្ងឺឆ្លង។

## ៦. ចំណីអាហារសម្រាប់មាន់

ការចិញ្ចឹមមាន់ដាក់ទ្រុងបង្ខាំង គឺ កូនមាន់ពឹងផ្អែកទាំងស្រុងទៅលើការផ្តល់ចំណីឱ្យ ។ តម្រូវការចំណីនេះ មានការកើនឡើង ទៅតាមអាយុ និង ទម្ងន់របស់វា ។ មាន់ត្រូវការចំណីដែលមានគុណភាពសម្រាប់ទ្រទ្រង់រាងកាយ ការរីកលូតលាស់ ផលិតកម្មស៊ុត និង សាច់។ កូនមាន់តូចៗ ដែលមានអាយុពី ១ ថ្ងៃ ដល់ ៤៥ ថ្ងៃ ត្រូវការចំណី ដែលមានគុណភាពល្អ និង មានគុណភាពខ្ពស់ដើម្បីការលូតលាស់របស់វា។

ចំណីជាប្រភពដ៏សំខាន់សម្រាប់ផ្តល់នូវថាមពល ជាតិសាច់ សារធាតុរ៉ែ និងវីតាមីនដែលធានាឱ្យមាន់មាន៖

- សុខភាពល្អ
- ការលូតលាស់ធំធាត់លឿន
- ការបន្តពូជល្អ

*ដូច្នេះ ក្នុងចំណីមាន់ត្រូវមានសមាសធាតុអ្វីខ្លះ?*

មាន់ត្រូវការនូវអាហារដែលមានគុណភាព និង បរិមាណគ្រប់គ្រាន់ ដូចជា ជាតិសាច់ ថាមពល វីតាមីន និង សារធាតុរ៉ែ ។ ក្រៅពីចំណី គេត្រូវផ្តល់ទឹកឱ្យមាន់ផឹក ឱ្យបានគ្រប់គ្រាន់ជាប្រចាំ។

### *៦.១. សមាសធាតុចំណី ដែលសំបូរជាតិសាច់ (ប្រូតេអ៊ីន)*

ប្រូតេអ៊ីន មានសារៈសំខាន់សម្រាប់ជួយការលូតលាស់របស់រាងកាយ សាច់ ស្បែក សម្រាប់ផលិតពង ។ ប្រូតេអ៊ីន អាចរកបានពី កន្ទក់ ចុងអង្ករ ត្រី ម្សៅត្រី ម្សៅត្រីក្រៀម កង្កែប ជន្លេន សត្វល្អិត ពពួកសណ្តែក សាច់ដូងស្ងួត ស្លឹកកន្ទុំថេត ស្លឹកដំឡូងឈើស្ងួត ត្រកួន ចកបាយទា ។ល។

ចំពោះប្រភេទរុក្ខជាតិបន្លែ ត្រូវហាលឱ្យស្ងួតល្អ និង បុកឱ្យម៉ត់មុនឱ្យមាន់ស៊ី ។ ចំណែកឯការកែច្នៃស្លឹកដំឡូងឈើ ស្ងួត ដែលជាប្រភពប្រូតេអ៊ីន អាចអនុវត្តដូចតទៅ៖

- យកតែស្លឹកដំឡូងមីផ្នែកខាងចុង ប្រហែល ៣ ទៅ ៤ តឹក
- កាប់ចិញ្ច្រាំស្លឹកដំឡូងមីឱ្យតូចល្អិត ហើយហាលឱ្យស្ងួតល្អ
- បន្ទាប់មកយកស្លឹក ដែលស្ងួតបុកឱ្យម៉ត់ជាម្សៅ
- លាយម្សៅស្លឹកដំឡូងមីស្ងួត ជាមួយសារធាតុផ្សំចំណីផ្សេងៗទៀត ដែលកសិករមាន។




រូបទី២២: ប្រភពចំណីផ្តល់នូវប្រូតេអ៊ីន

## ៦.២. សមាសធាតុចំណី ដែលសំបូរថាមពល

ជាសារធាតុមួយជួយផ្តល់ថាមពលក្នុងការរស់នៅ ផលិត ឬ ស៊ីចំណី និង ការធ្វើចលនា ។ ប្រភពថាមពល អាចមាននៅក្នុង ពោត ចុងអង្ករ កន្ទក់ កាកដូងស្ងួត មើមរុក្ខជាតិ កាកសំណល់បន្លែ ដំឡូងជ្វា កាកសំណល់ផ្លែឈើ ពពុះស្ករត្នោត ស្ករ កាកសំណល់ប្រេង-ខ្លាញ់....។




រូបទី២៣: ប្រភពចំណីអាហារផ្តល់ថាមពល

ចំពោះមើមដំឡូងមី និងត្រាវ គេអាចកាត់ហាលថ្ងៃ បន្ទាប់មកបុក ឬ កិនឱ្យម៉ត់ សម្រាប់ចំណីមាន់។

*ចូរប្រយ័ត្ន! ចិតយកសំបកមើមដំឡូងមីចេញ ពីព្រោះវាមានជាតិពុល។*

## ៦.៣. សមាសធាតុចំណី ដែលសំបូរជីវជាតិរ៉ែ

សារធាតុរ៉ែ ជាពិសេស ជាតិ កាល់ស្យូម មានសារៈសំខាន់ ធ្វើឱ្យឆ្អឹងលូតលាស់ល្អ និង បង្កើតសំបកស៊ុត ។ ចំពោះមាន់ដែលចិញ្ចឹមព្រលែង មិនមានបញ្ហាកង្វះសារធាតុរ៉ែទេ ព្រោះវាអាចរកបានដោយខ្លួនវា នៅក្នុងធម្មជាតិ។ កង្វះជាតិកាល់ស្យូម និងផូស្វ័រ បណ្តាលឱ្យមាន់លូតលាស់យឺត មេមាន់រាគពង (ពងចេញមក មានសំបក ទន់) និង ចឹកស៊ីពង ឬ សំបកពងខ្លួនឯង ។ ប្រភពនៃជីវជាតិរ៉ែ រួមមាន សំបកខ្យងខ្ចៅ ឆ្អឹង ត្រី អំបិល ថ្មើមសត្វ។



រូបទី២៤: ការផលិតម្សៅកាល់ស្យូម

## ៦.៤. សមាសធាតុចំណី ដែលសំបូរវីតាមីន

ចំណីដែលសំបូរទៅដោយវីតាមីន រួមមាន រុក្ខជាតិបៃតង ស្មៅ ផាងស្ពៃ ត្រកួន ចក....។ល។ ចំពោះមាន់ ដែលលែងឱ្យដើររកស៊ីខ្លួនឯង ពុំសូវមានបញ្ហាកង្វះវីតាមីន ទេ ព្រោះវាអាចស៊ីស្មៅ និង រុក្ខជាតិពណ៌បៃតង បានគ្រប់គ្រាន់។




រូបទី២៥: រុក្ខជាតិសំបូរវីតាមីន

### តើត្រូវរៀបចំថ្នាលស្មៅ និង បន្លែជាចំណីមាន់ យ៉ាងដូចម្ដេច?

កសិករ គួរតែធ្វើថ្នាលដាំស្មៅច្រើនប្រភេទ លាយជាមួយត្រកួននៅជិតផ្ទះ ឬ ជិតទ្រុងមាន់ ដើម្បីងាយស្រួលផ្គត់ផ្គង់ចំណីមាន់ ដែលជួយកាត់បន្ថយការចំណាយលុយទិញ ឬ ចំណាយពេលវេលាច្រើនសម្រាប់ដើររក ។ មុននឹងផ្ដល់ឱ្យមាន់ស៊ីត្រូវហាន់វាឱ្យល្អិតៗ ជាមុន រួចហើយយកទៅច្របល់លាយជាមួយចំណីផ្សំផ្សេងៗទៀត។



រូបទី២៦: ថ្នាលដាំស្មៅលាយជាមួយត្រកួន



រូបទី២៧: ហាន់ស្មៅ និងត្រកួនឱ្យល្អិតៗ

## ៦.៥. ការចិញ្ចឹមជន្លេនក្រហមសម្រាប់ជាចំណីបំប៉នបន្ថែម

### ៦.៥.១. តើជន្លេនក្រហម មានសារៈប្រយោជន៍អ្វីខ្លះ?

- ងាយស្រួលចិញ្ចឹម
- ជន្លេនសំបូរដោយប្រូតេអ៊ីន
- ផ្តល់ជាចំណីជាតិសាច់ (ប្រូតេអ៊ីន) សម្រាប់ឱ្យមាន់លូតលាស់ល្អ
- ជួយកាត់បន្ថយការចំណាយលើចំណីសម្រាប់ចិញ្ចឹមមាន់



រូបទី២៨: ពូជជន្លេនក្រហម

### ៦.៥.២. តើត្រូវចិញ្ចឹមជន្លេនយ៉ាងដូចម្តេច ដើម្បីឱ្យលូតលាស់ល្អ?

#### ក-ទីកន្លែងសមស្របសម្រាប់ចិញ្ចឹមជន្លេន

- មានទីទួលមិនលិចទឹក ឬ ទឹកហូរកាត់
- មានផ្ទៃដីបាតរាបស្មើ
- មិនមានសំបុកស្រមោចនៅក្បែរ
- ធានាសុវត្ថិភាពពីការបំផ្លាញពីកត្តាផ្សេងៗ

#### ខ-របៀបរៀបចំការចិញ្ចឹមជន្លេន

ដើម្បីឱ្យបានជោគជ័យ ត្រូវអនុវត្តជាបន្តបន្ទាប់ ដូចខាងក្រោម ៖

- ដាក់របាព័ទ្ធជុំវិញ ២ ជាន់ផុតពីដី ដែលមានទទឹង១,២ម៉ែត្រ បណ្តោយ ពី ២,៥ម៉ែត្រ ទៅ ៣ម៉ែត្រ និង កំពស់ ០,៣ម៉ែត្រ (៣តឹក)។
- របាខាងក្រោមមានកំពស់ពីដី ០,១៥ម៉ែត្រ និងរបាខាងលើមានកំពស់ពីដី ០,៣ម៉ែត្រ (៣តឹក)។

- ជញ្ជាំង និងបាត ក្រាលដោយផ្ទាំងកៅស៊ូក្រាស់ រួចចោះរន្ធតូចៗនៅបាត
- ដាក់លាមកគោស្រស់កំរាស់ ០,១ម៉ែត្រ (១តឹក)
- ស្រោចទឹកឱ្យសើម ទើបដាក់ពូជជន្លេន បន្ទាប់មកអាចស្រោចទឹកពីលើបន្តិចទៀត
- ធ្វើដំបូលការពារកំដៅ និងភ្លៀងឱ្យបានជិតល្អ
- ធ្វើគម្របពីលើដើម្បីការពារពីការស៊ីបំផ្លាញពីសត្វផ្សេងៗ (ដូចជាសត្វគីង្គក់ ហ៊ីង កង្កែប ថ្លែន ស្រមោច...)





<u>រូបទី២៩</u>: រៀបចំកន្លែងចិញ្ចឹម និងដាក់លាមកគោ

<u>រូបទី៣០</u>: ស្រោចទឹកឱ្យសើម





<u>រូបទី៣១</u>: ការដាក់ពូជជន្លេន

<u>រូបទី៣២</u>: កាធ្វើដំបូលការពារកំដៅ និង ភ្លៀង

## <u>*គ-របៀបថែទាំ និងផ្តល់ចំណី*</u>

- ស្រោចទឹក ២ថ្ងៃម្តង ការពារកុំឱ្យស្ងួត
- បន្ថែមចំណីដោយលាមកគោ ៣ ថ្ងៃ ម្តង

## <u>*ឃ-ការផ្តល់ចំណី(ជន្លេន)ឱ្យមាន់ស៊ី*</u>

- រយៈពេល ២ ខែអាចប្រមូលផលជន្លេនឱ្យមាន់ស៊ីបាន
- អាចផ្តល់ឱ្យមាន់ស៊ី ពី ៣ ទៅ ៤ ជន្លេន សម្រាប់មាន់មួយក្បាល ក្នុង ១ថ្ងៃ



<u>រូបទី៣៣</u>: ការដាក់ជន្លេនឱ្យមាន់ ជាចំណីបន្ថែម

# ៧. ការផ្តល់ចំណីអាហារមាន់

## ៧.១. ចំណីមេបា និង មាន់ធំ

ត្រូវផ្តល់ចំណីឱ្យមាន់បាន ពី២ ទៅ ៣ដង ក្នុងមួយថ្ងៃ ដោយលាយបញ្ចូលគ្នារវាងចំណីបាវ (ផ្សំស្រេច) ៥០% និង ចំណីដែលមានក្នុងភូមិ ៥០% (ដូចជាៈ ជាមួយកន្ទក់ ចុងអង្ករ និងស្រូវ ជាដើម)។ បន្ថែមលើនេះ ត្រូវហាន់ ឬ ចិញ្ច្រាំ ត្រកួន ឬ ចំណីបៃតង ផ្សេងៗទៀត សម្រាប់លាយជាមួយចំណីគ្រាប់ សម្រាប់ឱ្យមាន់ស៊ីបន្ថែម ទៀត។




រូបទី៣៤: ការលាយចំណីជាមួយបន្លែ (ចក ស្មៅត្រកួន...) និងការផ្តល់ឱ្យមាន់ស៊ី

## ៧.២. ចំណីកូនមាន់

ចំពោះកូនមាន់អាយុក្រោម ១ខែ ត្រូវផ្តល់ចំណីបាវគ្រាប់ល្អិត (ផ្សំស្រេច) ឱ្យបានច្រើនដង (ពី ៤ ទៅ ៥ ដង) ក្នុងមួយថ្ងៃ ។ ពេលមាន់អាយុជិត ១ខែ ត្រូវលាយបន្ថែមជាមួយចុងអង្ករ និង កន្ទក់ម៉ត់លេខ១ ។ ក្នុងរយៈកាលអាយុក្រោម ៣អាទិត្យ ត្រូវផ្តល់ចំណីផ្សំស្រេចសម្រាប់កូនមាន់ ហើយបន្ទាប់ពីនេះ ត្រូវលាយ ចំណីដូចជាចុងអង្ករ ពោត... ដែលកិនឱ្យល្អិតៗ ដើម្បីឱ្យកូនមាន់ងាយស្រួលលេបចូល ។ ជាដំបូង ត្រូវលាយ ជាមួយចំណីផ្សំដែលមានក្នុងភូមិ ប្រហែល ២០% និង ១ អាទិត្យបន្ទាប់ប្រហែល ៣០%។





រូបទី៣៥: ការផ្តល់ចំណីកូនមាន់ដែលមានប្រូតេអ៊ីនខ្ពស់

## ៨. ការផ្តល់ទឹក

មាន់ត្រូវការទឹកផឹកគ្រប់ពេលវេលា ដើម្បីការលូតលាស់ និង ផលិតកម្មពង ។ មាន់អាចស្លាប់ ប្រសិនបើគ្មានទឹកផឹក រយៈពេល ២៤ ម៉ោង។ ត្រូវផ្តល់ទឹកស្អាតជានិច្ច និង គ្រប់ពេល។

- មេមាន់ ១០ ក្បាល ត្រូវការទឹក ៤ លីត្រ ឬ ច្រើនជាងនេះ ក្នុងមួយថ្ងៃ
- កូនមាន់ ១០ ក្បាល ត្រូវការទឹក ១ កែវ ក្នុងមួយថ្ងៃ



រូបទី៣៦: ការផ្តល់ទឹកស្អាតដល់មាន់ផឹក

# ៩. ជីវសុវត្ថិភាព និង ការធ្វើអនាម័យ

សុខភាពមាន់ គឺជាគន្លឹះដ៏សំខាន់ សម្រាប់ការចិញ្ចឹម។ កសិករស្ទើរតែទាំងអស់ មានការខាតបង់ ដោយសារការផ្ទុះឡើងនូវជម្ងឺឆ្លង កាចសាហាវ ដែលសំលាប់មាន់ ស្ទើរគ្មានសល់ក្នុងមួយឆ្នាំៗ។

- ជម្ងឺបង្កឡើងដោយវីរុស គ្មានថ្នាំព្យាបាលទេ
- ជម្ងឺបណ្តាលមកពីបាក់តេរី អាចព្យាបាលបានខ្លះ ដោយប្រើថ្នាំអង់ទីប៊ីយូទិច
- ជម្ងឺបណ្តាលមកពីបរាសិត (ព្រូន អង្កែ...) ព្យាបាលដោយថ្នាំទំលាក់ព្រូន ឬ សំលាប់អង្កែ។

មាន់អាចចម្លងជម្ងឺយ៉ាងរហ័សពីមួយទៅមួយ តាមរយៈកាកសំណល់ លាមក ទឹកសំបោរ ។ ជួនកាល អ្នកចិញ្ចឹម មិនអាចមើលដឹងថា មាន់ណាមួយមានផ្ទុកជម្ងឺឡើយ។

## ៩.១. អនាម័យកន្លែងចិញ្ចឹម

- សំអាតព្រៃជុំវិញកន្លែង (ទ្រុង)ចិញ្ចឹម
- លប់ដីគ្រលុក ដក់ទឹក ឱ្យបានស្អាតល្អ
- ត្រូវក្រាលបាតទ្រុងជាមួយអង្កាម ឬ កំទេចអាចម៍រណារ
- ក្នុងកន្លែងមាន់ដេក (ទ្រុង) ត្រូវបោសសំអាត កើបលាមកមាន់ចេញរាល់ថ្ងៃ
- ត្រូវសម្លាប់មេរោគ និង បរាសិត (ក្នុង ទ្រុង និងធ្លាចិញ្ចឹម) រៀងរាល់មុនពេលដាក់មាន់ យ៉ាងតិច ១ អាទិត្យ ដោយបាចកំបោរសដើម្បី កុំឱ្យមាន់ឆ្លងមេរោគ។




រូបទី៣៧: ការសម្លាប់មេរោគដោយបាចទឹកកំបោរខាងក្រៅ និងក្នុងទ្រុងមាន់មុនពេលបញ្ចូលមាន់

## ៩.២. អនាម័យចំណីអាហារ និង ទឹកផឹក

- មិនត្រូវយកទឹកកខ្វក់មកឱ្យមាន់ផឹកទេ។ ត្រូវផ្លាស់ប្តូរទឹកថ្មីមួយដងក្នុងមួយថ្ងៃ
- ចំណីដុះផ្សិត ផ្អូម មិនត្រូវផ្តល់ឱ្យមាន់ស៊ីទេ

## ៩.៣. ការរៀបចំការចិញ្ចឹម

- ត្រូវរៀបចំដាក់តាមប្រភេទ និងជំនាន់របស់វា (ក្រុមមេបា កូនជំទង់ កូនតូចៗ)
- មាន់ទិញ ឬ យកមាន់ចូលថ្មី ត្រូវរក្សាទុកវាដោយឡែកដាច់ពីគេ ចំនួន ១៤ថ្ងៃ ។ បន្ទាប់មក បើសិនវាមានសុខភាពល្អ ទើបដាក់ចូលជាមួយមាន់ចាស់បាន។



រូបទី ៣៨: មុនបញ្ចូលមាន់ថ្មី ត្រូវរក្សាទុកយ៉ាងតិច ២ អាទិត្យ ដើម្បីតាមដានសុខភាពមាន់

## ៩.៤. អនាម័យការឆ្លងពីក្រៅ និង ឧបករណ៍សម្ភារៈចិញ្ចឹម

- មុនពេលចូលក្នុងទ្រុងមាន់ ត្រូវសម្លាប់មេរោគ ពិសេសដោយទឹកកំបោរ ជ្រលក់ស្បែកជើង ដែលមានដាក់នៅមាត់ច្រកចូលទ្រុង ជាមុនសិន ។
- ហាមមិនឱ្យមនុស្សពីក្រៅ (អ្នកដើរទិញមាន់ អ្នកចិញ្ចឹមកន្លែងផ្សេង) ចូលក្នុងកន្លែងចិញ្ចឹមមាន់
- ស្នូកទឹក ស្នូកចំណី ត្រូវឧស្សាហ៍លាងសំអាតជារៀងរាល់ថ្ងៃពេលផ្លាស់ប្តូចំណីឬ ទឹកឱ្យមាន់ស៊ីផឹក
- ប្រសិនបើមាន់ងាប់ ត្រូវកប់ ឬ ដុតចោល ។ មិនត្រូវបោះវាចោល ពាសវាលពាសកាល នោះទេ ។
- មិនត្រូវបរិភោគមាន់ ដែលងាប់ដោយសារជម្ងឺ ទេ ។





រូបទី ៣៩: ការកប់ ឬ ដុតបំផ្លាញចោល មាន់ដែលងាប់ដោយសារជម្ងឺ





រូបទី៤០: ដាក់ទឹកកំបោរថ្មនៅមាត់ច្រកចូល ដើម្បីសំអាតបាតស្បែកជើងមុនពេលចូលក្នុងទ្រុងមាន់

## ១០. ការការពារជម្ងឺមាន់

### ១០.១. ការចាក់ថ្នាំបង្ការ (វ៉ាក់សាំង)

ជម្ងឺមាន់ ជាជម្ងឺកាចសាហាវ មានការរាលដាលខ្លាំង និង បណ្តាលឱ្យមាន់ងាប់ច្រើន។ ហើយជម្ងឺភាគច្រើន ជាជម្ងឺ មិនអាចព្យាបាលបាន ដូច្នេះ វិធីដែលល្អប្រសើរបំផុត គឺ ការចាក់ថ្នាំបង្ការការពារ (វ៉ាក់សាំង) ជាមុន ។ លក្ខណៈទូទៅរបស់វ៉ាក់សាំង គឺៈ

- វ៉ាក់សាំងជាថ្នាំសម្រាប់បង្ការការពារជម្ងឺ មិនមែនជាថ្នាំសម្រាប់ព្យាបាលទេ
- សត្វដែលអាចចាក់វ៉ាក់សាំងបាន គឺ នៅពេលដែលវាមានសុខភាពល្អ
- វ៉ាក់សាំង ១មុខ អាចការពារជម្ងឺបានតែ ១មុខ ប៉ុណ្ណោះ
- ថ្នាំការពារខុសគ្នា មានវិធីប្រើខុសគ្នា (ផ្លូវបញ្ចូលថ្នាំ)
- ថ្នាំការពារជម្ងឺដូចគ្នាតែផលិតដោយក្រុមហ៊ុនខុសគ្នា ក៏អាចមានវិធីប្រើប្រាស់ខុសគ្នាដែរ ។ ដូច្នេះ គប្បីត្រូវដឹងឱ្យបានច្បាស់ពីវិធីប្រើប្រាស់ និង កំរិតប្រើប្រាស់វ៉ាក់សាំងនិមួយៗ ។
- វ៉ាក់សាំង ដែលនៅសល់ពីការប្រើប្រាស់ត្រូវដុតចោល
- អ្នកត្រូវកត់ត្រា ថ្ងៃ ខែ និង ចំនួនមាន់ចាក់វ៉ាក់សាំង
- ត្រូវចាក់ថ្នាំការពារដល់មាន់ទាំងអស់ និង ចាក់បានទៀងទាត់ ទើបមានប្រសិទ្ធិភាព។

តារាងកម្មវិធីចាក់ថ្នាំការពារជម្ងឺមាន់

| អាយុ | ឈ្មោះវ៉ាក់សាំងការពារជម្ងឺ | ផ្លូវបញ្ចូលវ៉ាក់សាំង | រំលឹកឡើងវិញក្រោយចាក់ |
|---|---|---|---|
| ពី ៣ ទៅ ៥ ថ្ងៃ | ជម្ងឺ ដង្កោកាច់ (ញ៉ូកាស I 2) | បន្តក់ក្នុងភ្នែក / ច្រមុះ | ៦ ខែ |
| ពី ៧ ទៅ ១០ ថ្ងៃ | ជម្ងឺ អុតមាន់ | ជួសស្បែកផ្ទាំងស្លាបរង | ១ ឆ្នាំ |
| ២ ខែ | ជម្ងឺ អាសន្នរោគ | ចាក់សាច់ដុំ | ៦ ខែ |

បញ្ជាក់: ក្នុងករណីមាន់ទុកសម្រាប់ធ្វើមេ និងបា ត្រូវចាក់រំលឹកឡើងវិញ ពី ៥ ទៅ ៦ខែ ម្តង (ជម្ងឺញ៉ូកាស ជម្ងឺអាសន្នរោគ និង ជម្ងឺរលាកផ្លូវដង្ហើម)



រូបទី៤១: ការបន្តក់ភ្នែក-ច្រមុះ (ជម្ងឺញូកាស)



រូបទី៤២: ជួសស្លាបរងកូនមាន់ (ជម្ងឺអុតបក្សី)



រូបទី៤៣: ការចាក់សាច់ដុំ (ជម្ងឺអាសន្នរោគ)

## ១០.២. កម្មវិធីទម្លាក់ព្រូន

ទម្លាក់ព្រូនលើកទី១ នៅពេលមាន់អាយុ ១ ខែ និង រំលឹកឡើងវិញ រយៈពេល ២ ទៅ ៣ ខែក្រោយមក ។ គេអាចប្រើថ្នាំ *មេបង់ដាសុល* សម្រាប់ទម្លាក់ព្រូនមាន់ ។ ក្នុងថ្នាំ *មេបង់ដាសុល* ១ គ្រាប់ សម្រាប់ដាក់ឱ្យមាន់ទម្ងន់រស់សរុប ៥ គីឡូក្រាម។

# ១១. ការកត់ត្រាចំណាយ ចំណូលផលិតកម្ម និង វិភាគសេដ្ឋកិច្ច

## ១១.១. ការកត់ត្រាចំណាយ ចំណូលផលិតកម្ម

ការកត់ត្រាទុកនូវតួរលេខចំណាយចំណូល មានសារៈសំខាន់ណាស់ ។ មាន ហេតុផលជាច្រើន ដែលគេចាំបាច់ត្រូវកត់ត្រាជាប្រចាំ ពីចំណាយ ចំណូល ផលិតកម្ម ។ ហេតុផលចំបងមួយចំនួន មានដូចជា៖

- ប្រសិនបើគ្មានការកត់ត្រាពីអ្វីដែលត្រូវបានចំណាយ ហើយអ្វីដែលបានចំណូលនោះទេ យើងនឹងមិនអាចដឹងបានទេ ថាតើ មុខជំនួញរបស់យើង ខាត ឬ ចំណេញ? ចូរចងចាំថា ការទទួលបានប្រាក់ចំណូលរាល់ថ្ងៃ មិនមានន័យថា យើងបានទទួលប្រាក់ចំណេញនោះទេ ។

- ប្រសិនបើយើងដឹងច្បាស់ពីមុខចំណាយ និង មុខចំណូលច្បាស់លាស់ យើងអាចរិះរកវិធីដើម្បី គ្រប់គ្រងជំនួញ ឱ្យបានកាន់តែល្អ កាន់តែបានចំណេញច្រើន។

- កំណត់ត្រាអាចត្រូវប្រើប្រាស់សម្រាប់ធ្វើផែនការចំណាយនៅពេលអនាគត ព្រោះយើងអាចដឹងពីតំលៃ និងធនធានដែលត្រូវចំណាយ ។

គោលដៅចំបងនៃធ្វើជំនួញ ឬ ផលិតកម្មអ្វីមួយ គឺរកបានចំណេញ និង កាន់តែចំណេញច្រើន ។ ប្រាក់ចំណេញជាផលសង (ឬ ភាពខុសគ្នាជាវិជ្ជមាន) រវាង ទឹកប្រាក់ចំណូល (បានមកពីលក់ផលិតផល ឬ សេវាកម្ម) និងទឹកប្រាក់ចំណាយទាំងអស់ ។ ចំណាយ អាចបែងចែកជា ២ ប្រភេទ គឺ ៖

(១) **ចំណាយថេរ** (មិនប្រែប្រួល [1]) គឺជា ចំណាយមូលធន ដូចជា ដី សំណង់ ឃ្លាំង រោងបណ្តុះផ្សិត ទ្រុងមាន់ គ្រឿងចក្រ...... ដែលមានតំលៃ (ត្រូវកាត់ រំលស់) ជាប្រចាំ ទោះជាមានការផលិត ឬក៏ គ្មាន ក៏ដោយ ។ ដោយសារឧបករណ៍ និង សម្ភារៈ ក្នុងមុខចំណាយថេរ ទាំងនេះ អាចប្រើបានច្រើនដង (ប្រើម្តង មិនអស់) ហើយ អាចប្រើនៅក្នុងផលិតកម្ម សារក្រោយៗទៀតនោះ គេត្រូវគិតរំលស់វា ជាច្រើនសារ។ ការកំណត់ចំនួនសាររំលស់ ថ្លៃឧបករណ៍ និង សម្ភារៈ ក្នុងប្រភេទចំណាយថេរនេះ អាចគិតបានច្រើនបែប ដូចជា តាមចំនួនសារ (ដង) ផលិតកម្ម តាមអាយុកាល (រយៈពេល) អាចនៅប្រើបានរបស់វា ...... ។
(២) **ចំណាយប្រែប្រួល** គឺជាប្រភេទចំណាយជាក់ស្តែងសម្រាប់ការផលិត ផលិតផល ឬ សេវាអ្វីមួយ ។ ការចំណាយប្រភេទនេះ រួមមាន វត្ថុធាតុដើម ដូចជា គ្រាប់ពូជ ដី ថ្នាំ កំបោរស ការរៀបចំដី ពលកម្ម ...... ដែលត្រូវការ ចាំបាច់សម្រាប់ផលិតរបស់ ឬ ផលិតផលអ្វីមួយ (ដូចជា ផ្សិតចំបើង មាន់ ជ្រូក......) ។

ដើម្បីឱ្យដឹងច្បាស់ ថាតើគោលដៅជោគជ័យជំនួញ សម្រេចបានត្រឹមណានោះ គេត្រូវការនូវព័ត៌មានជាចាំបាច់ដែលមិនអាចរកបាន ក្រៅពីការកត់ត្រាជាប្រចាំ និង បានត្រឹមត្រូវរបស់យើង នោះឡើយ ។ ការកត់ត្រា អាចផ្តោតលើការប្រមូលព័ត៌មានចាំបាច់ សម្រាប់វិភាគចំណាយ និង ចំណេញ និង តម្រង់ទិសមុខរបរ ឬ ផលិតកម្ម តាមពេលវេលាឱ្យចំ ឆ្លើយតបតម្រូវការទីផ្សារ និង ទៅអនាគតខាងមុខ ។ ខាងក្រោមនេះ ជាទម្រង់កត់ត្រា [2] សាមញ្ញមួយ ដែលកសិករ (ចិញ្ចឹមមាន់) អាចប្រើសម្រាប់កត់ត្រាចំណាយ ចំណូលរបស់ខ្លួន ។

---

[1] នៅពេលទិញ ឬ សាងសងហើយ (គឺថា បានចំណាយហើយ) ទោះបីប្រើ ឬ មិនប្រើក្តី សម្រាប់ការផលិតទំនិញ(ផលិតផល) អ្វីមួយ ក៏ដោយ ក៏គុណភាព (គឺវាក្លាយបន្តិចម្តងៗ ទៅជារបស់ចាស់ សឹករេចរិល...... ) ហើយ តំលៃរបស់វា នឹងត្រូវបាត់បង់បន្តិចម្តងៗ ទៅតាមនោះដែរ។

[2] តាមគំរូ សៀវភៅកត់ត្រាគ្រប់គ្រងកសិដ្ឋានកសិករ របស់គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ ទន្លេសាប។

ក. តារាងចំណាយ

ឈ្មោះផលិតកម្ម:.......................................

ថ្ងៃចាប់ផ្តើមផលិតកម្ម:...................................   ថ្ងៃបញ្ចប់ផលិតកម្ម:.........................

| ល.រ | មុខចំណាយ | ឯកតា | ចំនួន | តំលៃ ១ឯកតា | ទឹកប្រាក់សរុប |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |

ខ. តារាងចំណូល

ឈ្មោះផលិតកម្ម:.......................................

ថ្ងៃចាប់ផ្តើមផលិតកម្ម:...................................   ថ្ងៃបញ្ចប់ផលិតកម្ម:.........................

| ល.រ | មុខចំណូល | ឯកតា | ចំនួន | តំលៃ ១ឯកតា | ទឹកប្រាក់សរុប |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |

## ១១.២. ការប្រើប្រាស់ព័ត៌មានប្រមូលបាន សម្រាប់វិភាគចំណាយចំណូលផលិតកម្ម

ដើម្បីទទួលបានព័ត៌មាន ចាំបាច់ ត្រឹមត្រូវ គេត្រូវកំណត់ឱ្យបានច្បាស់ពីមុខចំណាយ និង ចំណូលទាំងអស់ ហើយកត់ត្រាបានជាប្រចាំ និង បានត្រឹមត្រូវពីព័ត៌មាន ដែលបានកំណត់ទាំងនោះ ។ ព័ត៌មានប្រមូលបានទាំងនេះ នឹងត្រូវប្រើសម្រាប់វិភាគសេដ្ឋកិច្ច (គឺ ថ្លៃដើមផលិតផល និង ប្រាក់ចំណេញ) របស់ផលិតកម្មណាមួយ ។ ខាងក្រោមនេះ គឺជា គំរូកត់ត្រា និង វិភាគចំណាយ និង ចំណូលនៃការចិញ្ចឹមមាន់ស្រុក របស់កសិករម្នាក់ នៅក្រុង សិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។



### ការវិភាគសេដ្ឋកិច្ចលើចិញ្ចឹមមាន់ស្រុក

កសិករឈ្មោះ: ឈាប ឆាត — ភូមិ ផាហ៊ុត សត្វ ក្រុង សិរីសោភ័ណ បន្ទាយមានជ័យ

បង្ហាញ ចិញ្ចឹមមាន់ស្រុក — (មេបាពូជ ៣២ក្បាល ដាក់ខណ្ឌក្នុងទ្រុងខណ្ឌជាប្លុក ចំនួន ៤ ។ កូនចិញ្ចឹមយកសាច់រយៈពេល ៣ខែកន្លះ។ ១ក្បាលទម្ងន់ប្រហែល ១,២ គីឡូក្រាម។

ថ្ងៃចាប់ផ្តើម: ថ្ងៃទី ១៥ តុលា ២០១១ — ថ្ងៃប្រមូលផល: ថ្ងៃទី ៣០ មករា ២០១២

| បរិយាយ | ឯកត្តា | ចំនួន | តម្លៃ/ឯកត្តា | សរុប | សរុបក្នុង១សារ |
|---|---|---|---|---|---|
| ១-ចំណូល | | | | | |
| ក- ប្រាក់ចំណូលពីលក់មាន់ | គីឡូក្រាម | 70 | 15.000 | 1.050.000 | 1.050.000 |
| ខ- ប្រាក់ចំណូលពីលក់អាចម៍មាន់ធ្វើជី | បាវ | 3 | 5.000 | 15.000 | 15.000 |
| ចំណូលសរុប | | | | | 1.065.000 |
| ២ក-ចំណាយ ប្រែប្រួល | | | | | |
| ពលកម្មថែទាំមាន់ទាំងអស់ (៣ ម៉ោង ក្នុង ១ថ្ងៃ រយៈពេល ១០៥ ថ្ងៃ) | នាក់-ថ្ងៃ | 8 | 10.000 | 80.000 | 80.000 |
| កំបោរស សម្រាប់ ១ ទ្រុង សិក្សា | បាវ (30 គីឡូ) | 1 | 10.000 | 10.000 | 10.000 |
| ចំណីសម្រាប់មេបា (៥០ ថ្ងៃ ត្រូវការបង្កបង្កើតពង/កូន) ៖ | | | | | |
| > មេបា ៥០ថ្ងៃ បង្កកំណើតពងក្រាប (ចំណីបាវ) | គីឡូក្រាម | 30 | 2.000 | 40.000 | 72.000 |
| > មេបា ៥០ថ្ងៃបង្កកំណើតពងក្រាប (ចំណីផ្សំ) | គីឡូក្រាម | 30 | 1.000 | 20.000 | 30.000 |
| ចំណីកូន (ចិញ្ចឹមលក់ជាសាច់ រយៈពេល ៣ខែកន្លះ)៖ | | | | | |
| > ចំណី (បាវ) សម្រាប់កូន ៥១ ក្បាល) | គីឡូក្រាម | 90 | 2.000 | 180.000 | 180.000 |
| > ចំណី (ផ្សំ) សម្រាប់កូន៥១ ក្បាល) | គីឡូក្រាម | 90 | 1.000 | 90.000 | 90.000 |
| - វ៉ាក់សាំង និង បញ្ចុះព្រូន | | | | | |
| > មេបា ១ ទ្រុង (៨ ក្បាល) | | | | | |
| ជម្ងឺអាសន្នរោគ Cholera | សរុប-សារ | 8 | 140 | 1.220 | 1.220 |
| ជម្ងឺញូកាស Newcastle | សរុប-សារ | 8 | 60 | 480 | 480 |
| > កូន ចិញ្ចឹមយកជាសាច់លក់ (៥១ ក្បាល) | | | | | |
| ជម្ងឺអាសន្នរោគ Cholera | សរុប-សារ | 51 | 140 | 7.140 | 7.140 |
| ជម្ងឺញូកាស Newcastle | សរុប-សារ | 51 | 60 | 3.060 | 3.060 |
| ជម្ងឺអុត Fowl pox | សរុប-សារ | 51 | 60 | 3.060 | 3.060 |
| - បញ្ចុះ/ទម្លាក់ព្រូន Deforming | សរុប-សារ | 60 | 40.000 | 1.600 | 1.600 |
| - ថ្នាំ TH4 បាញ់បង្ការជម្ងឺផ្តាសាយបក្សី | លីត្រ | 0,50 | 3.000 | 1.500 | 1.500 |
| សរុបចំណាយប្រែប្រួល (TVC) | | | | | 479.960 |
| ២ខ-ចំណាយមិនប្រែប្រួល/ថេរ | | | | | |
| ពលកម្មសាងសាងទ្រុង (12 នាក់-ថ្ងៃ ក្នុង ១ប្លុក) | នាក់-ថ្ងៃ | 12 | 10.000 | 120.000 | 4.000 |
| តំលៃរំលស់ មេបាមាន់ សម្រាប់ ១ ទ្រុង (៨ ក្បាល) | ក្បាល | 8 | 7.000 | 56.000 | 3.111 |
| សំភារៈសាងសង់ទ្រុង សម្រាប់ ១ ខណ្ឌ/ប្លុក | សរុប | 1 | 200.000 | 200,000 | 6.667 |
| ស្នូកចំណី (រំលស់) សម្រាប់ ១ ប្លុក/ខណ្ឌ/សារ | គ្រឿង | 2 | 10.000 | 20.000 | 6.667 |
| ស្នូកទឹក (រំលស់) សម្រាប់ ១ ប្លុក/ខណ្ឌ/សារ | គ្រឿង | 2 | 7.000 | 14.000 | 4.667 |
| ស្នប់បាញ់ថ្នាំសម្លាប់មេរោគ (រំលស់) សម្រាប់ ១ ប្លុក/ខណ្ឌ/សារ | គ្រឿង | 1 | 6.000 | 6.000 | 200 |
| សរុបចំណាយមិនប្រែប្រួល / ថេរ (TFC) | | | | | 15.112 |
| | | | | | |
| ២គ-ចំណាយសរុប (TC = TVC+TFC) | | | | | 495.072 |
| ៣ខ-ប្រាក់ចំណេញ (មួយសារ រយៈពេល ៣ ខែកន្លះ) ធៀបចំណាយ សរុប TC | | | | | 569.900 |

# កែសម្រួលដោយ៖

១- លោក **អ៊ុំ ណារិទ្ធ** : អ្នកជំនាញផ្នែកបសុសត្វ នៃគម្រោង TSTD ( 2013 )

២- លោក **លីវ លាងហ៊ី** ប្រធានក្រុមទីប្រឹក្សា / អ្នកជំនាញផ្នែកផ្សព្វផ្សាយ ផ្ទេរបច្ចេកវិទ្យា នៃគម្រោង TSTD

៣- លោក **ស៊ា វិសាលរដ្ឋ** : អ្នកជំនាញថ្នាក់ជាតិផ្នែកបសុសត្វ នៃគម្រោង TSTD មកពីនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល

### អនុញ្ញាតបោះពុម្ពផ្សាយ និងរក្សាសិទ្ធិដោយ

# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### ឆ្នាំ ២០១៣

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
#២០០ វិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ : ០១២ ៨២៦ ៦១៧
ទូរសារ : (៨៥៥) ០២៣ ២១០ ៩៤៨
អ៊ីម៉ែល : mak_soeun@camnet.com.kh



នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
បោះពុម្ពលើកទី ១: ឆ្នាំ ២០១៣ ចំនួន ១.០០០ ច្បាប់